# ក្រសួងសង្គមកិច្ច និង ការងារ

## ប្រកាស

**កំណត់សំគាល់** : លិខិតបទដ្ឋានរបស់ក្រសួងសង្គមកិច្ច និង ការងារ ដែលទើបនឹងចុះផ្សាយក្នុងរាជកិច្ច លេខ ៥ ថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ១៩៩៣ នេះ ដោយយោងតាមសំណើលេខ ២១១ សក.អក ចុះថ្ងៃទី ១២ ខែ តុលា ឆ្នាំ ១៩៩៣ របស់ ក្រសួងសង្គមកិច្ច និង ការងារ ។

ភ្នំពេញ , ថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ១៩៩៣

## ប្រកាសលេខ ១២ សក.អក.៩៣ស្តីពី
## បណ្ណើងបើក និង បិទសហគ្រាស

រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច និង ការងារ

****

- បានឃើញពិធីសម្ពោធន៍សភាធម្មនុញ្ញកាលពីថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ១៩៩៣
- បានឃើញសេចក្តីសំរេចចិត្តរបស់សភាលេខ ០៣ រសក. ៩៣ ចុះថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ១៩៩៣
- បានឃើញក្រឹត្យរបស់សម្តេចព្រះឧបយុវរាជ នរោត្តម សីហនុ ប្រមុខរដ្ឋនៃកម្ពុជា ចុះថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរដ្ឋាភិបាលជាតិបណ្តោះអាសន្ននៃកម្ពុជា
- បានឃើញច្បាប់ការងារ

## សំរេច

**ប្រការ ១** : នាយក ឬ ម្ចាស់សហគ្រាស និង គ្រឹះស្ថានឧស្សាហកម្ម រ៉ែ ពាណិជ្ជកម្ម សិប្បកម្ម កសិកម្ម សេវាកម្ម សហគ្រាសដឹកជញ្ជូនតាមផ្លូវគោក ឬ តាមទន្លេជាសាធារណៈ ឬ ជាពាក់កណ្តាលសាធារណៈ ឬ ឯកជនក្រៅសាសនា ឬ ក្នុងសាសនាទោះជាមានលក្ខណៈ ជាការបង្រៀនវិជ្ជាជីវៈ ឬ ជាការកុសលក៏ដោយ ព្រមទាំងអ្នកកាន់វិជ្ជាជីវៈសេរី និង អ្នកដឹកនាំសមាគម ឬ ក្រុមប្រភេទណាក៏ដោយ នៅមុនពេលបើកសហគ្រាសត្រូវតែធ្វើពាក្យប្តឹងបើកសហគ្រាស ទៅក្រសួងសង្គមកិច្ច និង ការងារ បន្ទាប់ពីមានការយល់ព្រមពើតំរោងផែនទីតាំងផ្សេងៗ ដូចជា រោងចក្រ រោងជាង ឬ ការិយាល័យនីមួយ ៗ រួចហើយ ។

ប្រការ ២ : ការដាក់ជូនពិនិត្យជាមុននូវផែនទីសំណង់ផ្សេង១ នោះត្រូវផ្ញើទៅនាយកដ្ឋានពេទ្យការងារ នៃក្រសួងសង្គមកិច្ច និង ការងារ តាមបែបបទដូចតទៅ :

- ធ្វើពាក្យសុំមួយច្បាប់មានបិទតែមប្រ៊ី ១៥០៖០០ ( មួយរយហាសិបរៀល )
- ភ្ជាប់នូវផែនទីរួមរបស់សហគ្រាស ដោយមានទាំងបទកក្សាអគ្គិសនី ប្រព័ន្ធការ ពារអគ្គីភ័យ ប្រព័ន្ធ ផ្គត់ផ្គង់ទឹកស្អាតអាចផឹកបាន ប្រព័ន្ធបញ្ចេញទឹកសំអុយ ឃ្លាំងទុកផលិតផលដែលមានគ្រោះថ្នាក់ កន្លែងដាក់សំរាម និង កាកសំណល់របស់រោងចក្រ ។

ប្រការ ៣ : សុំលិខិតនៃពាក្យប្តឹងបើកសហគ្រាសមានដូចតទៅ :

១- ពាក្យប្តឹងបើកសហគ្រាសយកតាមគំរូក្នុងឧបសម្ព័ន្ធ ទី ១ នៃប្រកាសនេះដោយមានបិទតែមប្រ៊ី ១៥០៖០០ ( មួយរយហាសិបរៀល ) ចំនួនពីរច្បាប់ ។

២- លិខិតបញ្ជាក់ពីក្រសួងសង្គមកិច្ច និង ការងារ អំពីការយល់ព្រមលើគំរោងផែនទីសំណង់ផ្សេង១ រោងចក្រ រោងជាង ឬ ការិយាល័យ " របស់សហគ្រាស ។

ចំពោះសហគ្រាសដែលបានបើកមុនកាលបរិច្ឆេទនៃការចេញប្រកាសនេះ អាចយកគំរោងផែនទីសំណង់ដែលរដ្ឋអំណាចមានសមត្ថកិច្ចចេញអោយ ឬ ធ្វើគំរោងប្លង់សារជាថ្មីបើសិនជាគ្មានមកជំនួសលិខិតបញ្ជាក់របស់ក្រសួងសង្គមកិច្ច និង ការងារខាងលើ ។

៣- ពាក្យប្តឹងស្តីពីបុគ្គលិកយកតាមគំរូឧបសម្ព័ន្ធ ទី ២ នៃប្រកាសនេះ ។

ចំពោះសហគ្រាសទាំងអស់នៅក្រុងភ្នំពេញ ត្រូវបញ្ជូនសំណុំលិខិតនៃពាក្យប្តឹងបើកសហគ្រាសខាងលើទៅនាយកដ្ឋានអធិការកិច្ចការងារនៃក្រសួងសង្គមកិច្ច និង ការងារ ចំណែកសហគ្រាសនៅតាមខេត្ត -ក្រុងផ្សេងទៀតត្រូវបញ្ជូនទៅ អធិការដ្ឋានសង្គមកិច្ច និង ការងារ ខេត្ត - ក្រុង នៃមូលដ្ឋានខ្លួន ។

ប្រការ ៤ : ចំពោះសហគ្រាសដែលបានដំណើរការមុនកាលបរិច្ឆេទនៃការចេញប្រកាសនេះត្រូវធ្វើសំណុំលិខិតនៃ ពាក្យប្តឹងបើកសហគ្រាសទៅក្រសួងសង្គមកិច្ច និង ការងារ យ៉ាងយូរបំផុត ៣ ខែ ( បីខែ ) បន្ទាប់ពីថ្ងៃចេញប្រកាសនេះជាផ្លូវការ ។

ប្រការ ៥ : សហគ្រាសទាំងអស់ដែលមានចង្អុលបង្ហាញក្នុង ប្រការ ១ ខាងលើ ត្រូវជូនដំណឹងមកនាយកដ្ឋានអធិការកិច្ចការងារនៃក្រសួងសង្គមកិច្ច និង ការងារ ចំពោះសហគ្រាសនៅភ្នំពេញ ឬ អធិការដ្ឋានសង្គម កិច្ច និង ការងារ ខេត្ត - ក្រុងនៃមូលដ្ឋានខ្លួន នូវគ្រប់សកម្មភាពផ្លាស់ប្តូរទីតាំងការកែប្រែរចនាសម្ព័ន្ធ ផលិតកម្ម និង ការបិទ ឬ បញ្ឈប់សកម្មភាពសហគ្រាសយ៉ាងយូរបំផុត ៣០ ថ្ងៃ ( សាមសិបថ្ងៃ ) បន្ទាប់ពីថ្ងៃមានការផ្លាស់ប្តូរយ៉ាងនេះ ឬ បន្ទាប់ពីថ្ងៃដែលមានបញ្ឈប់សកម្មភាពសហគ្រាស ។

**ប្រការ ៦ :** ការប្រព្រឹត្តិល្មើសចំពោះបទបញ្ញត្តិខាងលើនេះ ត្រូវពិន័យឬទទួលទោសតាមមាត្រា ២៨៨ នៃច្បាប់ការងារ ។

**ប្រការ ៧ :** ប្រកាសនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច និង ការងារ**

ហត្ថលេខា

**ស៊ុយ សែម**

****

**ភ្នំពេញ, ថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៩៣**

## ប្រកាសលេខ ១៥ សក.អក. ៩៣ស្តីពីការ
## បង្កើតសៀវភៅបើកប្រាក់

*********

រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច និង ការងារ

****

- បានឃើញពិធីសម្ពោធន៍សភាធម្មនុញ្ញកាលពីថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ១៩៩៣
- បានឃើញសេចក្តីសំរេចចិត្តរបស់សភាលេខ ០៣ រសក ៩៣ ចុះថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ១៩៩៣
- បានឃើញក្រឹត្យរបស់សម្តេចព្រះឧបយុវរាជ នរោត្តម សីហនុ ប្រមុខរដ្ឋនៃកម្ពុជា ចុះថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរដ្ឋាភិបាលជាតិបណ្តោះអាសន្ន នៃកម្ពុជា
- បានឃើញច្បាប់ការងារ

**សំរេច**

**ប្រការ ១ :** នាយកម្ចាស់សហគ្រាស ឬ គ្រឹះស្ថានណាមួយដែលមានចង្អុលបង្ហាញក្នុងមាត្រា ១៤ នៃច្បាប់ការងារ ត្រូវកាន់ដោយទៀងទាត់ជាដរាប នូវសៀវភៅបើកប្រាក់មួយ ដែលមានគំរូដូច ក្នុងឧបសម្ព័ន្ធ នៃប្រកាសនេះ ។